# «មនុស្សម្នាក់តែងតែមានជម្រើសនៅក្នុងជីវិតជានិច្ច»

ដោយ ឡូរ៉ា ម៉ាកដូណល់

ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩

ប្រែសម្រួលដោយ ទែន សុខស្រីនិត

ថ្ងៃនេះ មានដើមបណ្តឹងរដ្ឋប្បវេណីជាង៣០នាក់ បានចូលរួមតាមដានដំណើរការអង្គជំនុំជម្រះសេចក្តីប្រឆាំងនឹង កាំង ហ្គេកអ៊ាវ (ឌុច) ដែលក្នុងនោះដើមបណ្តឹងរដ្ឋប្បវេណី១០រូបបានអង្គុយនៅក្នុងបន្ទប់សវនាការ ហើយដោយឡែកអ្នកដែលនៅសេសសល់អង្គុយក្បែរខ្ញុំនៅក្នុងសាលសាធារណៈរបស់អង្គជំនុំជម្រះ ។ លើកលែងតែដើមបណ្តឹងរដ្ឋប្បវេណីបីរូបដែលអង្គុយនៅពីក្រោយក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនក្រុមជារៀងរាល់ថ្ងៃ នោះដើមបណ្តឹងប្បវេណីផ្សេងទៀតក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីទាំងដប់រូបនោះបានមកចូលរួមក្នុងអង្គជំនុំជម្រះសេចក្តីនេះ ដើម្បីជួបជាមួយនឹងមេធាវីរបស់ខ្លួន និងដើម្បីតាមដានដំណើរការរបស់តុលាការដែលសកម្មភាពទាំងនេះអាចជួយឲ្យពួកគេទទួលបាននូវសំណងថ្លៃខូចខាតតាមផ្នែកសីលធម៌ និងសំណងថ្លៃខូចខាតរួម ប្រសិនបើ ឌុច សម្រេចថា មានទោស ។ ដូចសព្វមួយដង ដោយសារតែប្រជាជនកម្ពុជាដែលស្ថិតក្នុងសម្លៀកបំពាក់សមរម្យកាន់នូវក្រដាសព័ត៌មាន មានចំនួនច្រើនជាងអ្នកស្រាវជ្រាវផ្នែកច្បាប់ជនជាតិបរទេស ដែលស្ថិតក្នុងសម្លៀកបំពាក់ជាអាវយឺតនោះ អង្គជំនុំជម្រះនៅក្នុងថ្ងៃនេះ ប្រៀបបីដូចជាព្រឹត្តិការណ៍ប្រវត្តិសាស្រ្តដ៏សំខាន់ដែលនឹងត្រូវបានកើតឡើង ជាជាងព្រឹត្តិការណ៍សម្រាប់ការស្រាវជ្រាវផ្នែកច្បាប់ដែលនឹងត្រូវបានពិភាក្សាវែកញែក ។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ បានកំពុងតែប្រឈមមុខនឹងអំពើសាហាវឃោរឃៅដែលបានកន្លងផុតទៅជាច្រើនទសវត្សរ៍មកហើយ ។ អំពើរសាហាវឃោរឃៅនេះ មានជាប់ពាក់ព័ន្ធនឹងមនុស្សជាច្រើនលាននាក់ ដែលត្រូវបានយកមកពិភាក្សាជាញឹកញាប់ទៅតាមព្រឹត្តិការណ៍បរិបទប្រវត្តិសាស្ត្រ ។ សរុបមក ការចូលរួមរបស់ប្រជាជនកម្ពុជាដ៏ច្រើនកុះករនេះ បានធ្វើឲ្យដំណើរការអង្គជំនុំជម្រះមានសភាពរស់រវើក ។

នៅចំពោះមុខអ្នកតាមដានដែលមានចំណាប់អារម្មណ៍ពីដំណើរការរបស់អង្គជំនុំជម្រះ សាក្សីជំនាញពីរបបខ្មែរក្រហមគឺ ក្រេក អេតឆេសាន់ បានបន្តការធ្វើកសិណសាក្សីរបស់លោក ។ ក្រេក អេតឆេសាន់ បានពន្យល់ប្រាប់ថាខណៈពេលដែលមន្ទីរសន្តិសុខទាំងអស់ បានប្រើប្រាស់ការវាយទាត់ការវាយ

នឹងរំពាត់ការធ្វើឲ្យថប់ដង្ហើម និងការឆក់នឹងចរន្តអគ្គិសនីទៅលើអ្នកទោសនោះគុកទួលស្លែង (មន្ទីរស-២១) បានអនុវត្តវិធីសាស្ត្រធ្វើទារុណកម្មមានលក្ខណៈធំដាង នេះរួមមានការដុតរាងកាយ ការដកក្រចកដៃឬជើង ការបន្តក់ទឹកអំបិលលើមុខរបួស ការធ្វើទារុណកម្មដោយសត្វពីស ការវាយបំបាក់ស្មា និងទម្រង់ធ្វើទារុណកម្មដោយទឹកជាច្រើនបែបទៀត ។ ក្រេក អេតឆេសាន់ ក៏បានចាត់ទុក«របបបង្អត់អាហារ»ដែលផ្តល់ឲ្យអ្នកទោសថា ជា«វិធីសាស្ត្រសម្លាប់ដែលមានឥទ្ធិពលតិចតួច» ។ លោកបណ្ឌិតក៏បានពន្យល់ពីរបៀបដែលវិធីសាស្ត្រធ្វើទារុណកម្មជា ទូទៅត្រូវបានផ្ទេរទៅឲ្យសមាជិកបក្សដោយផ្ទាល់ និងបានចាត់ ឌុច ជាអ្នកបណ្តុះបណ្តាលគោលការណ៍ក្នុងវិធីសាស្ត្រធ្វើទារុណកម្មនៅមន្ទីរស-២១ ។

ក្រេក អេតឆេសាន់ បានពន្យល់ប្រាប់ថា ការអនុវត្តធ្វើទារុណកម្មបានវិវត្តន៍រហូតនៅមន្ទីរស-២១ ដោយស្របទៅតាមវិធីសាស្ត្រទាញយកចម្លើយសារភាព ខុសពីមន្ទីរសន្តិសុខទាំងអស់ដែលទាញយកចម្លើយសារភាព មន្ទីរស-២១បានអនុវត្តការទាញយកចម្លើយសារភាពដែលមានលក្ខណៈតឹងរឹង និងល្អិតល្អន់ដោយបង្កើតជាដំណើរការមួយដែលបណ្តាលឲ្យមានចម្លើយសារភាពដ៏វែងនិងលម្អិត ហើយក្នុងករណីខ្លះ ចម្លើយសារភាពមានដល់ទៅមួយពាន់ទំព័រ ។ ក្រេក អេតឆេសាន់ បានផ្តល់ហេតុផលថា ករណីនេះកើតឡើងដោយសារតែកម្មាភិបាល និងសមាជិកបក្សជាន់ខ្ពស់ត្រូវបានសួរចម្លើយនៅមន្ទីរស-២១ ដូច្នេះអ្នកសួរចម្លើយមានចំណាប់អារម្មណ៍ច្រើនលើបុគ្គលទាំងអស់នេះ ។

ក្រេក អេតឆេសាន់ សូមសរសើរ ឌុច ចំពោះការអភិវឌ្ឍការអនុវត្តឲ្យមានបញ្ជីឈ្មោះអ្នករួមគំនិតក្បត់ក្នុងអំឡុងពេលសួរចម្លើយ ។ បញ្ជីឈ្មោះមួយប្រភេទត្រូវបានសរសេរដោយអ្នកទោស និងមួយប្រភេទផ្សេងទៀតបង្កើតឡើង ដោយអ្នកសួរចម្លើយតាមរយៈដំណើរការពិនិត្យលើចម្លើយសារភាព ។ បញ្ជីឈ្មោះជនក្បត់ទាំងអស់នេះ ផ្តល់ប្រយោជន៍យ៉ាងច្រើនដល់ថ្នាក់លើរបស់ ឌុច ហេតុដូច្នេះហើយថ្នាក់លើទាំងនោះបានតំឡើងតំណែង ឌុច ឲ្យធ្វើជាប្រធានមន្ទីរស-២១ ។ ឌុច មានទម្លាប់មួយធ្វើការកត់ត្រាលើចម្លើយសារភាពដែល ក្រេក អេតឆេសាន់ បានយល់ថា ជាការអនុវត្តការងារមួយដែល ឌុច បានអភិវឌ្ឍក្នុងអំឡុងពេលបំពេញការងារជាគ្រូបង្រៀនកាលពីមុនរបស់ខ្លួន ។ ឧទាហរណ៍ ការកត់ត្រាខ្លះ បានបង្អាប់ឲ្យអ្នកសួរចម្លើយអនុវត្តការធ្វើទារុណកម្ម ឬស្វែងរកព័ត៌មានជាក់លាក់ណាមួយពីចម្លើយសារភាពនោះ ដូចជា ការចូលរួមពាក់ព័ន្ធជាមួយនឹង សេ.អ៊ី.អា ឬ កា.ហ្សេ.បេ ។

ទាក់ទិននឹងចម្លើយសារភាព បញ្ហាភស្តុតាងបានកើតមានឡើង ដែលបញ្ហានេះបានកើតឡើងជាញយដង រហូតដល់សេចក្តីសម្រេចជាផ្លូវការត្រូវបានធ្វើឡើង ។ លោកប្រធានចៅក្រម និល ណុន បានក្រើនរំឭកភាគីទាំងអស់ថា អង្គជំនុំជម្រះសាលាដំបូងត្រូវគោរពទៅតាមមាត្រា១៥នៃអនុសញ្ញាស្តីពីការហាមឃាត់ការធ្វើទារុណកម្ម ។ ដូច្នេះឯកសាររបាយការណ៍បានបង្កើតឡើងដោយការធ្វើទារុណកម្មមិនត្រូវយកមកសំអាងជាធាតុនៃភស្តុតាងបានឡើយ លើកលែងតែឯកសាររបាយការណ៍នោះ ត្រូវបានធ្វើឡើងសម្រាប់ជាភស្តុតាងប្រឆាំងនឹងជនត្រូវចោទនៃអំពើទារុណកម្ម ។ នេះមានន័យថា ការពិតដែលថាចម្លើយសារភាពត្រូវបានធ្វើឡើងក្រោមការធ្វើទារុណកម្ម គឺជាអង្គហេតុមួយដែលអាចទទួលយកបាន ប៉ុន្តែខ្លឹមសាររបស់ចម្លើយសារភាពទាំងនេះ ដែលធ្វើឡើងក្រោយការធ្វើទារុណកម្មមិនអាចទទួលយកបានថាជាចម្លើយសារភាពមួយដែលពិតប្រាកដនោះបានទេ ។ ចៅក្រម ខាតវ៉ាយថ៍ បានគូសបញ្ជាក់ថា យ៉ាងហោចណាស់ ឥឡូវនេះអង្គជំនុំជម្រះសាលាដំបូង នឹងដោះស្រាយបញ្ហាចម្លើយសារភាពនេះ ដោយផ្អែកតាមមូលដ្ឋានរបស់ករណីមួយៗ ។ ប្រសិនបើដែលភាគីណាមួយចង់ពិភាក្សាពីខ្លឹមសាររបស់ចម្លើយសារភាព នោះអង្គជំនុំជម្រះសាលាដំបូងនឹងពិនិត្យពីលក្ខខណ្ឌដែលចម្លើយសារភាពនោះត្រូវបានធ្វើឡើងដើម្បីសម្រេចថា តើខ្លឹមសារទាំងនោះអាចដាក់ជាភស្តុតាងបានដែរឬយ៉ាងណា ។ ចៅក្រម ខាតវ៉ាយថ៍ បានបញ្ចេញមតិថា អង្គជំនុំជម្រះសាលាដំបូងមិនបានត្រៀមខ្លួនដើម្បីចេញសេចក្តីសម្រេចដាក់លាក់មួយទាក់ទិននឹងបញ្ហានេះនៅឡើយទេ ដោយសារតែបញ្ហាភស្តុតាងនេះកំពុងដាក់ជូនចំពោះការិយាល័យរបស់សហចៅក្រមស៊ើបអង្កេត ។

ដោយព្យាយាមសម្រួលដល់ភាពចម្រូងចម្រាស់ ដែលកើតមាននៅក្នុងកសិណសាក្សីកាលពីពេល ព្រឹក ប្រាំងស័រ រូ មេធាវីការពារក្តីអន្តរជាតិ បានចោទសួរសំណួរអស់ជាច្រើនម៉ោងដើម្បីឆ្លុះបញ្ចាំងឲ្យឃើញថា របបខ្មែរក្រហមគឺជា«របបនៃអំពើព្រៃផ្សៃ»ដែល ឌុច គឺជាកម្មាភិបាលសាមញ្ញ ហើយមិនអនុញ្ញាតឲ្យដឹងពុំអ៊ីទេ ។ ឌុច គ្មានជម្រើសផ្សេងក្រៅពីគោរពតាមបញ្ជា និងអនុវត្តតាមមាគ៌ាបក្សដែលផ្សព្វផ្សាយពីមជ្ឈិមបក្សទេ ។ ដោយលើកឡើងសារជាថ្មីម្តងទៀតពីកសិណសាក្សីរបស់លោក ដែលធ្វើឡើងកាលពីម្សិលមិញ ទាក់ទិននឹងគោលនយោបាយរបស់ខ្មែរក្រហម ស្តីពីការលាក់ការណ៍សម្ងាត់ និងការគ្រប់គ្រងបញ្ហាព័ត៌មានដ៏តឹងរឹង ក្រេក អេតឆេសាន់ បានបញ្ជាក់ថា ឌុច គឺជាបុគ្គលលើកលែងម្នាក់ក្នុងចំណោមកម្មាភិបាលបក្សផ្សេងទៀត ពីព្រោះថា ឌុច ជាញឹកញាប់មានទំនាក់ទំនងផ្ទាល់ជាមួយនឹងថ្នាក់ដឹកនាំជាន់ខ្ពស់ដូចជា សុន សេន និង នួន ជា ហើយម្យ៉ាងទៀត ឌុច អាចនឹងទទួលបានព័ត៌មានសម្ងាត់តាមរយៈការសួរចម្លើយលើសមាជិកជាន់ខ្ពស់របស់បក្សនៅឯមន្ទីរស-២១ ។ ក្រេក

*អេតឆេសាន់ បានអះអាងពីកសិណសាក្សីរបស់លោកដែលធ្វើឡើងកាលពីម្សិលមិញថា វិធីសាស្ត្រទាញយកចម្លើយសារភាពរបស់ ឌុច បានបណ្តាលឲ្យមានការបោសសម្អាត ដែលមានលក្ខណៈរាលដាល ។ យោងតាមសម្តីរបស់ ឌុច បានអភិវឌ្ឍ និងបង្កើតវិធីសាស្ត្រសម្រាប់ការទាញយកចម្លើយសារភាព ដែលអ្នកទោសត្រូវបានបង្ខំឲ្យផ្តល់ឈ្មោះមនុស្សដែលស្គាល់ក្នុងរយៈពេលជាច្រើនសប្តាហ៍ និងច្រើនខែ ។ បញ្ជីឈ្មោះមនុស្សទាំងនោះ ត្រូវបានប្រើប្រាស់ដើម្បីចាប់ខ្លួនជនក្បត់ថ្មី ដែលដំណើរការសួរចម្លើយដដែលនេះត្រូវបានអនុវត្ត ។ ដូច្នេះ ឌុច មានការទទួលខុសត្រូវចំពោះ«ការកើនឡើងយ៉ាងច្រើន» លើចំនួនជនរងគ្រោះ ។ ក្រេកអេតឆេ សាន់ បានអះអាងថា ការចាប់ខ្លួនសួរចម្លើយនេះគឺជាភាពផុយផល់មួយដែល ឌុច បានអនុវត្តវិធីសាស្ត្រនេះដោយរួមផ្សំជាមួយនឹងភាពជ្រុលនិយមរបស់មជ្ឈិមបក្ស ដែលបង្កជាផលប៉ះពាល់ដ៏មហន្តរាយមួយ ។*

*ហ្វ្រង់ស៊័រ រូ បានជម្រុញសួរ ក្រេក អេតឆេសាន់ ថា «តើឌុចមានជម្រើសផ្សេងទៀតដែរឬទេ?» ក្រេក អេតឆេសាន់ បានផ្តល់យោបល់ថា «មនុស្សម្នាក់តែងតែមានជម្រើសក្នុងជីវិតជានិច្ច ។» បន្ទាប់មកទៀត ហ្វ្រង់ស៊័រ រូ បានចង្អុលបង្ហាញថា ការដែល ឌុច មានជីវិតរស់រាននេះបានឆ្លុះបញ្ចាំងឲ្យឃើញថា តើ ឌុច អាចនឹងមិនមានជីវិតរហូតមកដល់សព្វថ្ងៃនេះទេ ប្រសិនបើ ឌុច មិនគោរពតាមបញ្ជារបស់ថ្នាក់លើ ។ អង្គជំនុំជម្រះនៅក្នុងថ្ងៃនេះ បានបញ្ចប់ទៅដោយ ហ្វ្រង់ស៊័រ រូ បានលើកឡើងពីសេចក្តីអំណះអំណាងរបស់លោកកាលពីម្សិលមិញដែលថា ៖ «ខ្ញុំមិនចូលចិត្ត ហើយមិនដែលចូលចិត្តអ្នករងទោសជំនួសអ្នកដទៃឡើយ» ។ នៅថ្ងៃច័ន្ទ ទី៨ ខែមិថុនា អង្គជំនុំជម្រះសេចក្តីប្រឆាំងនឹង ឌុច នឹងបន្តចោទសួរសំណួរ ឌុច ពីការអនុវត្តគោលនយោបាយរបស់ខ្មែរក្រហមនៅមន្ទីរស-២១ និងពីជម្លោះប្រដាប់អាវុធរវាងកម្ពុជា និងវៀតណាម ។ អង្គបុរេជំនុំជម្រះអាចនឹងរៀបចំដំណើរការនីតិវិធីនៅសប្តាហ៍ក្រោយ ប៉ុន្តែមិនទាន់មានការប្រកាសជាផ្លូវការ ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅឡើយទេ ។*